# ការបង្ហាញពីរបៀប
# សំពះខ្មែរ
# KHMER SALUTATION



១៨.
០៦

UNESCO
CAMBODIA

និពន្ធ និង រៀបរៀងដោយ
សំ សំអាង និង ខួន សំអាត

**សមាគមវប្បធម៌ខ្មែរ**

១៥C ផ្លូវលេខ ១៩៨៦
បង្កាត់ឫស្សីកែវ ខ័ណ្ឌ ឫស្សីកែវ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ១៦-៨២៣-០៨៩ (៨៥៥)១២-៨៤៩-២៤២
អ៊ីមែល: Samangsam@aol.com

**KHMER CULTURE ASSOCIATION**

15 C, Street 1986
Sangkatt Roeussey Keo, Khann Roeussey Keo
Phnom Penh
CAMBODIA
Tel : (855) 16-823-089, (855) 12-849-242
E-mail: Samangsam@aol.com

រក្សាសិទ្ធិ © ២០០២

Copyright © 2002
Sam-Ang Sam and
Sam Ath Nguon

**ទីប្រឹក្សា :**

ពេជ្រ ទុំក្រវិល
ឯម ធាយ
ហ៊ឹម ណាឡា

*Advisors:*

Tum Kravel Pich
Theay Em
Nala Him

**រូបថតដោយ :**

ងួន សំអាត
សំ សំអាង
ហ៊ឹម ណាឡា

*Photographs by:*

Sam Ath Nguon
Sam-Ang Sam
Nala Him

បោះពុម្ពនៅ ព្រះរាជាណាចក្រកម្ពុជា
ឧបត្ថម្ភថវិកាដោយ អង្គការយូណេស្កូកម្ពុជា
បោះពុម្ពលើកទី១ ចំនួន ២.៥០០ ច្បាប់
ខែមករា ឆ្នាំ២០០២

Printed in Cambodia: 2,500 copies

Sponsored by UNESCO

January 2002



# ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជា
# និង
# សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ

## HIS MAJESTY PREAH BAT SAMDECH PREAH
## NORODOM SIHANOUK
## KING OF CAMBODIA
## AND
## HER MAJESTY PREAH REACH AKKA MOHESEY
## NORODOM MUNINEATH SIHANOUK
## QUEEN OF CAMBODIA



យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ
សម្តេច ហ៊ុនសែន
នាយករដ្ឋមន្ត្រី
នៃ ព្រះរាជាណាចក្រកម្ពុជា
និងលោកជំទាវ ប៊ុន រ៉ានី ហ៊ុនសែន
ចំពោះការឧបត្ថម្ភជ្រោមជ្រែងលើកស្ទួយវប្បធម៌ខ្មែរ

We would like to express our profound gratitude to
Samdech HUN SEN
Prime Minister of Cambodia
for his support and promotion of khmer cultre

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE



សិក្សាស្រាវជ្រាវ និង ចងក្រង

ក្រោមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់

របស់ សម្ដេចព្រះរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី

រដ្ឋមន្ត្រី

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

**A RESEARCH PROJECT UNDER THE DIRECTION OF**

**HER ROYAL HIGHNESS SAMDECH PREAH REAM**

**NORODOM BUPPHA DEVI**

**MINISTER OF CULTURE AND FINE ARTS**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២

# ព្រះសន្ទេស

ខ្ញុំមានបីតិសោមនស្សរីករាយជាខ្លាំង ចំពោះការរៀបចំសៀវភៅប្រកបដោយឧត្តមគតិខ្ពស់ ក្នុងការរួមចំណែកជួយលើកស្ទួយ និង អភិវឌ្ឍន៍ប្រទេសកម្ពុជា លើវិស័យវប្បធម៌ លើការរៀបចំចងក្រង ថែរក្សានូវទំនៀមទំលាប់ប្រពៃណី កេរដំណែលពីដូនតាស្តីពី ***របៀបសំពះខ្មែរ*** យកមករៀបចំបោះពុម្ពចែកជូនដល់កូនខ្មែរ និង ផ្សព្វផ្សាយដល់អន្តរជាតិ ដើម្បីឱ្យគេបានយល់ និង ស្គាល់ពីតម្លៃវប្បធម៌ខ្មែរ ដែលជាជាតិដ៏ចំណាស់មួយមានប្រវត្តិសាស្ត្រវប្បធម៌ និង អារ្យធម៌ដ៏យូរលង់ក្នុងតំបន់អាស៊ីភាគអាគ្នេយ៍នេះ ។

ជាទីបញ្ចប់ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ខ្ញុំសូមប្រសិទ្ធិពរជ័យឱ្យការបោះពុម្ពសៀវភៅដ៏ប្រណីតនេះ បានសំរេចជោគជ័យដូចបំណងជាភិយ្យោភាព ។

សម្តេចព្រះរាជបុត្រីព្រះរាម **នរោត្តម បុប្ផាទេវី**

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## FOREWORD

I am very pleased with the research that was invested in this book. It is an important contribution to the development of Khmer culture. The publication of ***"Khmer Salutation"*** *is* essential for the cultural edification of our younger generation as well as for disseminating information around the world in regard to Cambodia's ancient and rich cultural heritage.

On behalf of the Ministry of Culture and Fine Arts, I would like to convey my best wishes for the success of this wonderful and important publication.

HRH Princess NORODOM Buppha Devi
Minister of Culture and Fine Arts
Phnom Penh, Cambodia

# និវេទនកថា

កេរមតិកវប្បធម៌អរូបី របស់ប្រទេសមួយ រាប់បញ្ចូលទាំងគ្រប់ទម្រង់សិល្បៈវប្បធម៌ ប្រពៃណីបុរាណ និងប្រជាប្រិយ ។ កេរដំណែលទាំងអស់នេះ ត្រូវបានបន្តដោយផ្ទាល់តាមភាសា និងកាយវិការ ពីជំនាន់មួយទៅជំនាន់មួយ ហើយឆ្លងកាត់ភាពច្នៃប្រឌិត និងកាលសម័យនៃការបង្កើតថ្មី ។ មតិកវប្បធម៌អរូបី នៃអារ្យប្រទេសមួយ រួមមាន ភាសា វោហាសាស្ត្រ តន្ត្រី សិល្បៈរបាំ ចម្រៀង របៀបស្លៀកពាក់ និងពិធីទំនៀមទម្លាប់ផ្សេងៗ ។

សម្រាប់ពលរដ្ឋខ្មែរ មតិកវប្បធម៌អរូបី គឺជាប្រភពអត្តសញ្ញាណដ៏សំខាន់ ដែលបានចាក់ឫសយ៉ាងជ្រៅក្នុងប្រវត្តិសាស្ត្រជាតិខ្លួន ។ មតិកជាតិខ្មែរ បានផ្ទេរពីជំនាន់មួយទៅជំនាន់មួយ តាមរយៈកាយវិការ និងពិធីទំនៀមផ្សេងៗ ទស្សនវិទ្យា តម្លៃនៃក្រមសីលធម៌ គុណធម៌ ព្រមទាំងមនោគតិ ដ៏ប្រណីតថ្លៃថ្លានៃបុព្វបុរស ។

សៀវភៅនេះគឺជាការកត់ត្រាយ៉ាងល្អមួយ ក្នុងការស្រាវជ្រាវពី របៀបសំពះ ដែលជាអត្តសញ្ញាណប្រពៃណីខ្មែរ ប្រារព្ធក្នុងគារវកិច្ច ឬ ការគោរពគួរសមគ្នាទៅវិញទៅមក ដែលខេមរជនគ្រប់រូប តែងបដិបត្តិជាបវេណីរៀងមក ។ របៀបគោរពសំពះគ្នានេះ អនុលោមទៅតាមវ័យ ឋានៈ និងសង្គមបរិយាកាស ដែលពួកគេរស់នៅ ។ ដោយហេតុផលនេះហើយ របៀបធ្វើគារវកិច្ចដោយសំពះ គឺជាប្រភពពតិមាន ដ៏ពិសេសមួយទាក់ទងដល់តម្លៃគុណធម៌ និងចរិយាធម៌ ក្នុងសង្គមខ្មែរ ។

អង្គការយូណេស្កូ កំពុងជួយឧបត្ថម្ភគាំទ្រ រក្សាការពារ និងស្តារឱ្យរស់ឡើងវិញ នូវកេរមតិកវប្បធម៌អរូបីជាតិកម្ពុជា ។ យើងខ្ញុំមានកិត្តិយសក្រៃលែង ចំពោះវិភាគទានព្រះតម្រិះផ្តួចផ្តើមដ៏ថ្លៃថ្លាឧត្តមរបស់ព្រះអង្គម្ចាស់ក្សត្រី សម្តេចព្រះរាម នរោត្តម បុប្ផាទេវី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។ នៅក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងនូវក្តីសរសើរដ៏ស្មោះស្ម័គ្រ ព្រមទាំងសូមផ្តល់នូវកម្លាំងចិត្ត ដល់បុគ្គលិកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាគមវប្បធម៌ខ្មែរ និងជាពិសេសអ្នកនិពន្ធសៀវភៅនេះ សូមបន្តខិតខំប្រឹងប្រែងក្នុងបំណងជួយរក្សាការពារនូវកេរដំណែលវប្បធម៌ខ្មែរឱ្យបានគង់វង្សចីរកាលតទៅ ។

លោក អេធៀន ក្លេម៉ង់

តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

## FOREWORD

The intangible heritage of a country embraces all forms of traditional and popular culture. These creations are transmitted orally or by gesture, and are modified over a period of time through a process of collective recreation. The intangible heritage of a giving country includes, among others, oral traditions, customs, languages, music, dance and rituals.

For Cambodian population, intangible is the vital source of an identity that is deeply rooted in their history. Cambodian have transmitted from generation to generation, through gestures and rituals, philosophy, values, moral code and ways of thinking which are unique to them.

The present book constitutes well-documented research about the *Sampeah*, the traditional Khmer sign of salutation or mutual recognition which is intimately known and practised by every Khmer. The way of saluting varies according to the age or the social scale of the persons involved. For this reason, *Sampeah* is a special source of information regarding the values and codes inherent to Cambodian society.

As UNESCO is supporting Cambodia in preserving and revitalising its national intangible cultural heritage, we are very honoured to have contributed to this important initiative of Her Royal Highness Samdech Preah Ream Norodom Buppha Devi, Minister of Culture and Fine Arts. On this occasion, I would also like to encourage the staff of the Ministry of Culture and Fine Arts and the Khmer Culture Association, the authors of this publication, to continue to devote all necessary efforts to preserve Cambodia cultural heritage.

Etienne Clément,
UNESCO Representative in Cambodia

៦១៤.១០៦

# ការបង្ហាញពីរបៀបសំពះខ្មែរ

# KHMER SALUTATION



និពន្ធនិងរៀបរៀងដោយ
សំ សំអាង និង ងួន សំអាត
BY SAM-SAM ANG AND SAM ATH NGUON

LIBRARY
៦៦២៩/០២

សមាគមវប្បធម៌ខ្មែរ
KHMER CULTURE ASSOCIATION

# មាតិកា

# Contents


**ទំព័រ**

**Page**

សេចក្តីថ្លែងអំណរគុណ
Acknowledgements ........................................................ 1

អារម្ភកថា
Preface.......................................................................... 2

សំពះ
Sampeah or Salutation..................................................... 4

អត្ថន័យរបស់សំពះ
Meanings of Sampeah ...................................................... 5

របៀបសំពះ
Sampeah Manner ............................................................ 6

ខ្នាតសំពះ
Sampeah Positions .......................................................... 6

វិធីថ្វាយបង្គំព្រះមហាក្សត្រ
Royal Salutation.............................................................. 13

វិធីថ្វាយបង្គំគាល់
Thvay Bangkum Koal ..................................................... 13

វិធីថ្វាយបង្គំចំពោះវត្តមាន និង ថ្វាយបង្គំលា
Thvay Bangkum in the Presence of a King ........................ 13

វិធីសំពះក្នុងរបាំ
Sampeah in Dance Context .............................................. 17

វិធីក្រាបថ្វាយបង្គំក្នុងព្រះពុទ្ធសាសនា
Krab Thvay Bangkum in Religious Context ....................... 23

វិធីក្រាបសំពះក្នុងអាពាហ៍ពិពាហ៍
Krab Sampeah in Wedding Ceremony.............................. 31

ឯកសារពិគ្រោះ
References Cited ............................................................ 34

# សេចក្តីថ្លែងអំណរគុណ

ទូលព្រះបង្គំយើងខ្ញុំសូមថ្លែងអំណរព្រះគុណ ដ៏ជ្រាលជ្រៅជាទីបំផុតថ្វាយសម្តេចព្រះរាជបុត្រីព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈចំពោះព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ និងការគាំទ្រព្រមទាំងជំនួយស្មារតីគ្រប់បែបយ៉ាងពីព្រះអង្គ ធ្វើឱ្យសៀវភៅដ៏ប្រណីតនេះបានចាប់បដិសន្ធិ និង កើតបានជារូបរាងឡើង។ ចំពោះទីប្រឹក្សាជាទីគោរព មាន ឯកឧត្តម **ពេជ្រ ទុំក្រវិល** អ្នកគ្រូ **ឯម ធាយ** និង អ្នកគ្រូ **ហ៊ឹម ណាឡា** យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះគំនិតស្មារតី ញ៉ាំងឱ្យស្នាដៃនេះមានខ្លឹមសារ និង បាន សំរេចជាស្ថាពរ ។

សមាគមវប្បធម៌ខ្មែរសូមថ្លែងអំណរគុណដ៏ ជ្រាលជ្រៅដល់លោកស្រី **ហ្សេរ៉ាល់ឌីន យូនស្តាដធើរ** និង អង្គការមូលនិធិគ្រួសារ **អាល់ប៊ឺត យូនស្តាដធើរ** ព្រមទាំងអង្គការយូណេស្កូកម្ពុជា ដែលបានជួយឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅបង្ហាញពីរបៀប **សំពះខ្មែរ** នេះ។ ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកស្រី **សំ ចន្ទ្រមុន្នី** អ្នកស្រី **ពេជ្រ សុគន្ធាទី** កញ្ញា **សំ សារិន** កញ្ញា **ឈឹម ណាលីន** កញ្ញា **អ៊ុក សុលីជំនិត** កញ្ញា **សែម ឆវី** កញ្ញា **ហ៊ុខ ប៉ិច** កញ្ញា **ព្រុំ ម៉ារី** កញ្ញា **សុជាតិ អនុភាព** កញ្ញា **សុខ សុខៀន** កញ្ញា **មាឌ្យ សុភាព** លោក **ទ៉ាន់ ផេន** លោក **សំអាត សុវណ្ណា** លោក **ចាន់ និម្មិត** និង លោក **ទើខ សុភា** ដែលបានអនុញ្ញាតឱ្យក្រុមស្រាវជ្រាវថតជារូបភាពដែលមាននៅលើទំព័រដ៏ប្រណី តនៃសៀវភៅ **សំពះខ្មែរ** នេះ ។

ជាទីបញ្ចប់ទូលព្រះបង្គំយើងខ្ញុំ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅ ដល់អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ** ឯកឧត្តម **អ៊ុក សុជាតិ** ឯកឧត្តម **មីសែល ត្រាណេ** លោក **ហ្វ្រេត ហ្វ្រឹមប៊ើក** និង លោក **សួន ប៊ុនរិទ្ធ** ចំពោះការរិះគន់ស្ថាបនា និង ណែនាំផ្តល់ជាគំនិតល្អៗដើម្បីធ្វើឱ្យសៀវភៅនេះរឹតតែមានគុណភាពប្រសើរឡើង ។

# ACKNOWLEDGEMENTS

We would like to take this opportunity to express our profound thanks to Samdech Preah Ream Princess Norodom Buppha Devi, Minister of Culture and Fine Arts, for her blessing and insight into the creation of this work. We thank our advisors—H.E. Tum Kravel Pich, Mrs. Theay Em, and Mrs. Nala Him—for their valuable input in making this book meaningful and indeed a great one.

The Khmer Culture Association would like to express its heartfelt gratitude toward Mrs. Geraldine Kunstadter and the Albert Kunstadter Family Foundation as well as UNESCO for their generous support for this publication. We thank our handsome and beautiful friends, who were willing to pose for our photographs for this project.

Finally, we would like to thank H.R.H. Prince Sisowath Panara Sirivuth, H.E. Socheat Ouk, H.E. Michel Tranet, Mr. Fred Frumberg, and Mr. Bun Rith Suon for their constructive criticism, suggestions, and ideas at the early stage of our writing and preparing for the publication.

# អារម្ភកថា

ការគោរពជាចរិយាសម្បត្តិដ៏ល្អប្រសើររបស់ខ្មែរ។ ឯសំពះជាឥរិយាបថមួយដែលខ្មែរគ្រប់រូបទាំងចាស់ ទាំងក្មេង ប្រតិបត្តិ និងប្រកាន់ខ្ជាប់ក្នុងខ្លួន។ តាំងពីពេលធំដឹងក្តីកាលណាឪពុកម្តាយបង្រៀននិងប្រៀនប្រដៅកូនឱ្យចេះគោរពចាស់ទុំ ចេះជម្រាបសួរ ជម្រាបលាប្រកបដោយកាយវិការទន់ភ្លន់ ពោលគឺសំពះជាចំណែកមួយដ៏សំខាន់ នៅក្នុងជីវិត និង ជាសុជីវធម៌ដ៏ប្រពៃរបស់ខ្មែរ ។ ខ្មែរយើង ខ្លះមានចិត្តប្រកាន់ចំពោះភាពមិនគួរសម ។ គេមិនឱ្យដើរក្រោមខ្សែស្បៀងហាលខោអាវ។ គេមិនឱ្យដើររំលងមនុស្សដែលអង្គុយ ។ គេមិនឱ្យប៉ះឬកាន់ក្បាលអ្នកដទៃ ។ ហើយបើដើរកាត់មុខចាស់ទុំ ឬ អ្នកធំគេត្រូវឱន ។

ពេលវេលា និង ការវិវឌ្ឍន៍នៃការអប់រំ និង របៀបរស់នៅរបស់ខ្មែរ ជាកត្តាសំខាន់នៅក្នុងរឿងសំពះ ។ នាសម័យបច្ចុប្បន្ន ឥទ្ធិពលបរទេស និង បរទេសនិយមបាន នាំឱ្យខ្មែរ ជាពិសេសយុវជន និង យុវនារីដែលពុំសូវយល់ និង ឱ្យតម្លៃដល់ប្រពៃណី និង វប្បធម៌របស់ខ្លួនភ្លេច ឬ មិនគិតថាជារឿងសំខាន់ ចំពោះសុជីវធម៌ និង ទំនៀមទម្លាប់ ប្រពៃណី ។ យើងអាចជួបប្រទះនៅក្នុងឱកាសខ្លះ យុវជន និង យុវនារីយើងត្រវីដៃដាក់គ្នា សូម្បីតែចំពោះចាស់ទុំក៏ដោយ ។

<u>ខ្មែរយើងភាគច្រើននិយមសំពះជាងចាប់ដៃបែបបស្ចិមប្រទេសដោយ</u>

- រក្សាទំនៀមទម្លាប់ខ្មែរ
- គិតពីបញ្ហាអនាម័យ
- ចៀសវាងការប៉ះពាល់គ្នាដោយដៃ ជាពិសេសរវាងបុរស និងស្ត្រី
- ចៀសវាងការច្របាច់ដៃគ្នាខ្លាំងដែលអាចនាំឱ្យមានការឈឺចាប់
- ចៀសវាងមិនចំណាយពេលច្រើនដូចជាអ្នក ប្រដាល់សំពះទស្សនិកជនពីលើសង្វៀនប្រដាល់ ឬ អ្នកដឹកនាំនយោបាយសំពះប្រជាពលរដ្ឋពីលើវេទិកា ។

# PREFACE

It is a great challenge to write on a subject such as " សំពះ " *sampeah* which is intimately known and practiced by every Khmer, as one naturally grows up performing the *sampeah* both consciously and subconsciously everyday in life. Even a young child is taught and shown how to do *sampeah* as an act of respect and humbleness, which is very important in the Khmer etiquette. It is part of the Khmer life and mannerism. A Khmer person performs the *sampeah* when he is given something or a favor as a sign of gratitude. A child does the *sampeah* to his parents before leaving for and after returning from school. People also *sampeah* when meeting another person, particularly one older or higher in rank.

Every Khmer person grows up seeing and doing the *sampeah*. Thus, everyone assumes that he knows how to do this reverential act. Indeed, there are variances, in differing degrees, among the people of different classes of society in different loyalties, social surroundings of the country, and degrees of consciousness of a person about *sampeah* and Khmer customs and traditions.

Educated and modern individuals nowadays prefer hand-shaking over *sampeah*, as one might often notice. Nonetheless, to many Khmers, *sampeah* is preferred to hand-shaking for the reasons that:

- Khmer custom, tradition and mannerism ought to be preserved intact.
- Hand-shaking may hygienically contaminate one another through physical contact.
- Traditional Khmer women feel uncomfortable being touched by men, besides their intimate partners.
- In a big crowd, *sampeah* with a sweeping movement saves a great deal of time, such as in a boxing event, an act that is done by the boxers to the audience. Khmer leaders do that all of the times, as they salute the crowd during a public speech or meeting, instead of approaching everyone to *sampeah* or hand-shake them, which would be very time-consuming.

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅថ្នាក់កុមារដ្ឋាន មានដូចជាមុខវិជ្ជាអប់រំចរិយាសម្បត្តិនៅក្នុងកម្មវិធីសិក្សាដើម្បីឱ្យសិស្សានុសិស្សតូចៗ ទម្លាប់មានសុជីវធម៌ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ចេះរបៀបសំពះ ចេះគួរសម មានការគោរពប្រកបដោយចរិតសុភាពរាបសារ ។

ទូលព្រះបង្គំយើងខ្ញុំ ចងក្រងសៀវភៅនេះឡើង ក្នុងគោលបំណងចង់ថែរក្សានូវទំនៀមទម្លាប់របស់ខ្មែរ ផ្តល់ពត៌មានពីប្រវត្តិលក្ខណៈ និង សារៈសំខាន់នៃការសំពះខ្មែរ និង បង្ហាញជាគំរូអំពីរបៀបនៃការសំពះរបស់ខ្មែរ នៅពេលជួបគ្នា ពេលថ្វាយបង្គំព្រះ ព្រះសង្ឃ ពេលថ្វាយបង្គំព្រះមហាក្សត្រ និង នៅពេលផ្ទឹមអាពាហ៍ពិពាហ៍ ជាពិសេសសម្រាប់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០២



សំ សំអាង



ងួន សំអាត

During our school years in the 1950s, courses in mannerism were offered in the elementary school curriculum to teach young students early enough about their culture, respect, and humbleness preparing them to be respectful, accepted, and active members of the community.

This work is presented here with an intention to preserve a Khmer way, as aspect of Khmer culture. It can also serve as a guideline and principle on the placement and position of the *sampeah* posture—the budding lotus shape—and the ក្រាបសំពះ *krab sampeah* when greeting and saluting friends, older persons parents, teachers, the Buddha image or Buddhist monks, and king.

We hope that this small work will contribute and provide information, ideas, principles, and guidelines to our readers. The subject in question is certainly a familiar one with those who practice it. If there are any mistakes or there is information lacking however it might be, we would like to apologize and do hope that you will fill in any gaps left by this work.

Phnom Penh, January 12, 2002
Sam-Ang Sam
Sam Ath Nguon

# សំពះ

**សំពះ** ជាទំនៀមទម្លាប់របស់ខ្មែរ ធ្វើឡើងដើម្បី បង្ហាញពីការគួរសម និង គារវកិច្ច គោរពគ្នាទៅវិញទៅមក ។ ខ្មែរយើងសំពះឪពុកម្ដាយ ព្រះពុទ្ធរូប ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ គ្រូបាធ្យាយ ញាតិសន្ដាន និង អ្នកដែល មានឋានន្តរសក្ដិធំជាងខ្លួន។ នៅពេលទទួលអំណោយអ្វីមួយពីគេ ខ្មែរយើងលើកដៃសំពះដើម្បីសំដែងនូវអំណរគុណចំពោះម្ចាស់អំណោយ ។ នៅពេលសូមអភ័យទោសពីកំហុសអ្វីមួយដែលគេបានធ្វើ ខ្មែរយើងត្រូវលើកដៃសំពះ ។ នៅពេលដើរកាត់ ឬ ជិះកាត់មុខព្រះពុទ្ធរូប (ចំពោះអ្នកដែលមានជំនឿខ្លាំងទៅលើ ព្រះពុទ្ធសាសនា) គេក៏លើកដៃសំពះដែរ ។

កុលបុត្រ កុលធីតាខ្មែរ តែងតែសំពះ ឪពុកម្ដាយមុននឹងចេញទៅ និង ក្រោយពីត្រឡប់មកពីសាលារៀនវិញ។ ម្យ៉ាងទៀតខ្មែរយើងសំពះគ្នាទៅវិញទៅមកនៅពេលជួបគ្នា។ នៅក្នុងករណីដែលបុគ្គលណាម្នាក់ត្រូវចាកចេញពីកន្លែងមុនគេ បុគ្គលនោះត្រូវសំពះលាគេគ្រប់ៗគ្នាមុន មុននឹងចាកចេញទៅ ។ បន្ទាប់មកទើបអ្នកឯទៀត សំពះតបទៅវិញ ។ ចំពោះប្រជាជនខ្មែរមួយចំនួនដែលរស់នៅទីក្រុង ឬ អ្នករាជការ ធំក្ដី ឬ តូចក្ដីដែលនិយមរបៀបស៊ីវិល័យ គេច្រើននិយមចាប់ដៃគ្នាបែបបស្ចឹមប្រទេស ។ តែអ្នកខ្លះចាប់ដៃហើយថែមទាំងសំពះទៀតផងហាក់ដូចជាការចាប់ដៃទទេនៅមិនទាន់គ្រប់គ្រាន់ ។

អ្នកដែលមានអាយុតិចជាង ឬ ឋានន្តរសក្ដិតូចជាងត្រូវសំពះអ្នកដែលមានអាយុច្រើន ឬ ឋានន្តរសក្ដិធំជាងជាមុន ។ ចំណែកអ្នកដែលមានអាយុច្រើនជាង ឬ ឋានន្តរសក្ដិធំ ជាងមិនសំពះមុនទេ ឬ មិនតម្រូវ ឱ្យសំពះតបទៅអ្នកដែលមានអាយុតិចជាង ឬ ឋានន្តរសក្ដិតូចជាងទេ ដូច ជា តាមិនសំពះតបទៅចៅវិញទេ( វាំងតានិងចៅក្នុងកាលៈទេសៈខ្លះ) ។

យើងសូមបញ្ជាក់ថា មិត្តភក្ដិជិតស្និទ្ធគេមិនសំពះគ្នានៅពេលជួបគ្នា ឬ ពេលបែកគ្នាទេ ។

# *SAMPEAH*
# OR
# SALUTATION

The bending low of one's head to a person or thing in the form of a bow as a sign of obeisance or as a respectful attitude has survived to the present day. *Sampeah* is a form of greeting and respect, or better yet, mutual salutation or recognition, which is very essential in Khmer society. The Khmers pay respect to parents, Lord Buddha, monks, king and queen, teachers, uncles, aunts, older individuals and persons higher in rank.

Khmer etiquette implicitly requires that a junior in age or rank initiates a *sampeah* as a sign of respect to a senior accompanied at the same time with a slight bow. A person sitting on a chair before a high personage bends his head a little and holds his hands in a budding lotus shape placed somewhere between the face and chest. Or instead of having the hands posed in a budding lotus shape, the fingers may be clasped or the hands held one upon the other. Where a person is receiving something from a senior, he will raise his hands as a *sampeah* to the giver as a polite gesture of thanks before or after receiving it. When one is asking someone's pardon or favor, one usually makes such a *sampeah* too.

The person who is inferior in age or rank in the Khmer social scale initiates such a movement of the hands and the person receiving the salutation immediately reciprocates. This formality is not strictly adhered to by individuals who are on intimate terms. The Khmer salutation may be rendered while sitting, standing, walking or even lying in bed during an illness. In rendering a salutation while standing to a most respected person who is sitting, one, as a decorum of good manners, will stoop or bend down the head at the same time. When taking leave, the departing person will offer a salute in the same manner, followed in turn by a corresponding salute of the other person.

Psychologically, if a person receiving a *sampeah* from a junior is egotistically conscious of his superiority, he will return the *sampeah* with hands raised to a position not higher than the chest. If, by virtue of his great age or rank, he is not obliged to make a *sampeah* in return, he may merely raise his right hand side-wise and with a nod, or nod only, as favorable recognition or approval. In most cases a superior person seldom performs a *sampeah* first when meeting or greeting a person of inferiority.

# អត្ថន័យរបស់សំពះ

**បង្គំ** សំពះ ឬក្រាបសំពះឆ្ពោះទៅរកអ្នកដែលគួរ គោរព (វចនានុក្រមខ្មែរសម្ដេច ជួន ណាត ១៩៦៧ ទំព័រ ៥២៩) ។

**ក្រាបបង្គំគាល់ ឬ ក្រាបថ្វាយបង្គំគាល់** ចូលថ្វាយបង្គំ ហើយអង្គុយគាល់ (ទំព័រ ៥២៩) ។

**ក្រាបបង្គំទូល** ចូលក្រាបថ្វាយបង្គំទូលផ្ទាល់មាត់ ឬ ក្រាប ទូលដោយលិខិត (ទំព័រ ៥២៩-៥៣០) ។

**ថ្វាយបង្គំ ឬក្រាបបង្គំ** សំពះ ឬ ក្រាបសំពះដោយការ គោរព (ទំព័រ ៥៣០) ។

**បួងសួង** បន់ - បន់ស្រន់ - សំបូងសម្រួង ពោលពាក្យប្រកាស (ទំព័រ ៨៥៦) ។

**ប្រណម្យ** លើកកម្បង់អញ្ជលីសំពះ (ទំព័រ ៦៤៧) ។

**អញ្ជលី** ក្រពុំម្រាមដៃ - ការផ្គុំម្រាមទាំង១០គោរព (ទំព័រ ១៥៨៥) ។

**ប្រណម្យអញ្ជលី** លើកកម្បង់អញ្ជលីប្រណម្យ (ទំព័រ ១៥៨៥) ។

**សំពះ** លើកដៃ ទាំងពីរផ្គុំម្រាមទាំង១០ ឆ្ពោះត្រង់ទៅរកបុគ្គល ទៅរកទី ឬ វត្ថុដែលគួរគោរព (ទំព័រ ១៤២៤) ។

**សំពះការ** ក្រាបសំពះតាមបែបបទក្នុងវេលាដែលខ្លួន រៀបអាពាហ៍ពិពាហ៍ ។

**សំពះគ្រូ** សំពះគោរពចំពោះគ្រូ ឬ ចំពោះគុណគ្រូដែល បាន បង្រៀនមន្តវិជ្ជាការ ឬ សិល្បៈសា ស្រ្តផ្សេងៗ ។

**សំពះងារ ឬថ្វាយបង្គំងារ** ក្រាបថ្វាយបង្គំ តាមបែបបទ ចំពោះព្រះករុណាជាអង្គម្ចាស់ជីវិត ទទួលឋានន្តរសក្តិ ព្រះមេត្តាប្រោសព្រះរាជទានតែងតាំង ។

**សំពះពេលា** សំពះព្រះអាទិត្យទទួលពេលា មានឫក្សដែល ហោរបានកំណត់ឱ្យក្នុងពិធីអាពាហ៍ពិពាហ៍ ។

**សំពះលា** សំពះ ពោលពាក្យ លាគ្នា ។

**សំពះសួរ** សំពះបុគ្គលណាដែលគួរគោរពបញ្ចេញវាចាសួរសុខ ទុក្ខផង ។

**សំពះសុំអភ័យទោស** សំពះអង្វរសុំឱ្យគេអត់ទោសឱ្យ ។

**សំពះអ្នកតា** សំពះចំពោះរូបអ្នកតាដែលសន្មត់ថាសក្តិសិទ្ធិសុំ ឱ្យជួយ (ទំព័រ ១៤២៤) ។

Normally a senior will return the *sampeah* of a child with a nod or other appropriate gestures only, as a sign of approval or goodwill. Of course, there is an exception, if the child is a prince or an honorable member of a high dignitary's family.

When sitting, standing or passing before a high personage, or elder, one should assume the attitude of meekness by stooping or bending down one's head or body so that it is not level to or above the head of the personage. If the personage is sitting on a chair, one should stoop low when passing. This attitude applies equally to a personage who is walking.

## MEANINGS OF *SAMPEAH*

*Bangkum* Saluting or bending down and saluting a respectable person.

*Krab bangkum koal* or *Krab thvay bangkum* Entering to salute while sitting.

*Krab bangkum toul* Entering to salute verbally or by letter.

*Thvay bangkum* Saluting or bending down and saluting with respect.

*Buong suong* Praying by declamation.

*Pranamm* Raising the budding lotus hands to salute.

*Anchali* Putting the ten fingers together to salute.

*Pranamm anchali* Raising the budding lotus hands to salute.

*Sampeah* Raising both hands with the ten fingers together pointing upward, palm to palm, to salute a respectable person or object; gesture of respect.

*Sampeah kar* Bending down and saluting in a wedding ceremony.

*Sampeah krou* Saluting, with respect, teachers or teacher's gratitude for having taught magical arts or artistry.

*Sampech ngear* or *Thvay bangkum ngear* Bending down and saluting the king for bestowing a title or position.

*Sampeach pelea* Saluting the sun to receive the blessing moment as told by astrologer in the wedding ceremony.

*Sampeah lea* Saluting to say goodbye.

*Sampeah suor* Saluting respectable person with words of greeting.

*Sampeah saum toh* Saluting to beg for forgiveness.

*Sampeah neak ta* Saluting the guardian spirit effigy asking for help.

## របៀបសំពះ

ខ្មែរយើងសំពះដោយលើកដៃទាំងពីរផ្គុំគ្នា ជារាងផ្កាឈូកក្រពុំដាក់នៅពីមុខត្រង់ទៅលើ ហើយផ្ទៀងចុងដៃទៅ មុខបន្តិចកម្ពស់ចន្លោះដើមទ្រូង និង មុខដោយដាក់ដើមដៃទាំងពីរនៅជាប់នឹងដងខ្លួន កែងដៃមិនចេញច្រងាង ។ ការសំពះរបស់ខ្មែរមាន ភាពខុសគ្នាបន្តិចបន្តួចទៅតាមទីកន្លែង កម្រិត សតិសម្បជញ្ញៈ និង ស្មារតី ព្រមទាំងចំណេះដឹង និង ការយល់របស់បុគ្គលម្នាក់ៗអំពីសំពះ ។

## ខ្នាតសំពះ

កម្ពស់ ឬកម្រិតកន្លែងពោលគឺខ្នាតដាក់ដៃប្រណម្យជារឿងសំខាន់នៅក្នុងសំពះខ្មែរក៏មានន័យថា កាលណាដៃដាក់កាន់តែខ្ពស់ឯកម្រិត និង ទំហំនៃការធ្វើគារវកិច្ចគោរព ក៏កាន់តែខ្ពស់ និង ធំទៅតាមនោះដែរ ។

- **១- កម្ពស់ដើមទ្រូង** វ័យ ឬ ឋានៈស្មើ ឬ ប្រហាក់ប្រហែលគ្នា មិត្តភក្តិ
- **២- កម្ពស់មាត់** វ័យចាស់ជាង ឋានៈធំជាងឬចៅហ្វាយនាយ
- **៣- កម្ពស់ចុងច្រមុះ** ឪពុកម្តាយ ជីដូនជីតា គ្រូបាអាចារ្យ
- **៤- កម្ពស់ចិញ្ចើម** ព្រះមហាក្សត្រ ព្រះសង្ឃ ឬ វត្ថុសក្តិសិទ្ធិ សក្ការៈ
- **៥. កម្ពស់ចិញ្ចើមឡើងលើ** ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ឬ បួងសួងសំបួងសម្រួង

- ➢ មនុស្សមានអាយុស្មើគ្នា ឬបុណ្យសក្តិស្មើគ្នាគប្បីលើកដៃសំពះគ្នាទៅវិញទៅមក ដោយដាក់ដៃត្រឹមដើមទ្រូង ។
- ➢ អ្នកដែលមានឋានៈតូច សំពះអ្នកដែលមានឋានៈធំ ឬចៅហ្វាយនាយ គប្បីលើកដៃប្រណម្យ ហើយ ដាក់ម្រាមដៃនៅត្រឹមមាត់ ។
- ➢ កូនសំពះឪពុកម្តាយ ចៅសំពះតាយាយ សិស្សសំពះគ្រូ គប្បីលើកដៃឡើង ហើយ ដាក់ម្រាមដៃនៅត្រឹមច្រមុះ ។
- ➢ រាស្ត្រសាមញ្ញ ថ្វាយបង្គំ ព្រះមហាក្សត្រ ព្រះសង្ឃ ឬវត្ថុសក្តិសិទ្ធិសក្ការៈ គប្បីលើកដៃប្រណម្យ ហើយដាក់ចុងម្រាមដៃ នៅត្រង់ប្រជុំចិញ្ចើម ។

## *SAMPEAH* MANNER

The Khmer sign of salutation or mutual recognition is to raise both hands, join palm to palm, lightly touching the body somewhere between the face and chest. The higher the hands are raised, the greater is the respect and courtesy conveyed.

The raising of the hands to *sampeah*, and the lowering of the hands to a normal position after the *sampeah* are never done with a swift movement but rather in a graceful manner in a slow motion. The upper parts of the arms remain close to the sides of the body, without the elbow extended. The hands, joined palm to palm, are both held far out from the body in an erect position, but bent slightly inward.

It should be noted that the placing of one's hands in a budding lotus position or *sampeah* is never higher than the forehead. In the ordinary way of life, a *sampeah* in such a manner is done mostly by a prisoner, who is asking for shelter or relief, or a beggar asking for alms.

## *SAMPEAH* POSITIONS

1. Chest level
2. Mouth level
3. Nose level
4. Eyebrow level
5. Above the eyebrow level

- ➢ People of the equal age or rank ought to *sampeah* each other by placing the budding lotus hands at the chest level.
- ➢ A younger person or lower in rank ought to *sampeah* an older person or higher in rank by placing the budding lotus hands at the mouth level.
- ➢ Children and grandchildren or students *sampeah* their parents and grandparents or teachers by placing the budding lotus hands at the nose level.
- ➢ The commoners ថ្វាយបង្គំ *thvay bangkum (sampeah)* a king, a monk, or a sacred object by placing the budding lotus hands at the eyebrow level.
- ➢ Prayers to the Lord Buddha or Gods ought to assume the *sampeah* posture by placing the budding lotus hands above the eyebrow level.

- អ្នកដែលសំពះបន់ស្រន់ ឬ រំឭកគុណចំពោះព្រះពុទ្ធ ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម គប្បីលើកដៃប្រណម្យកម្ពស់ពីចិញ្ចើមឡើងទៅ ។

សំពះអាចធ្វើឡើងនៅពេលឈរ អង្គុយ ឬ ដេកនៅលើគ្រែ ( ចំពោះមនុស្សឈឺ ) ។ ធម្មតាគេសំពះដោយឱនក្បាលចុះបន្តិចផង ។ ការលើកដៃសំពះត្រូវធ្វើឡើងដោយយឺតៗទន់ភ្លន់មិនរហ័សពេកទេ ឬ ប្រញាប់ឡើយ ។ នៅក្នុងស្ថានភាពធម្មតាគេមិនសំពះដោយដាក់ដៃខ្ពស់ហួសថ្ងាសទេ លើកលែងតែអ្នកទោស ឬ អ្នកសុំទានដែលអាចធ្វើដូច្នេះដើម្បីសំដែងនូវអំណរអរគុណដ៏ជ្រាលជ្រៅចំពោះអ្នកដែលសន្ដោស ឬ លើកលែងទោសឱ្យគេ និងម្ចាស់អំណោយពោល គឺគុណដ៏ធ្ងន់លើសលប់ ។



៥_ កម្ពស់ចិញ្ចើមឡើងលើ : ទេវតាព្រះឥន្ទ្រ ព្រះព្រហ្ម ឬ បួងសួង
សំបួងសម្រួង (FOREHEAD LEVEL)



៤_ កម្ពស់ចិញ្ចើម : ព្រះមហាក្សត្រ ព្រះសង្ឃ ឬ
វត្ថុស័ក្តិសិទ្ធិ សក្ការៈ ( EYEBROW LEVEL)



៣_ កម្ពស់ចុងច្រមុះ : មាតាបិតា ជីដូនជីតា
ឬ គ្រូបាអាចារ្យ (NOSE LEVEL)



២_ កម្ពស់មាត់ : វ័យចាស់ជាង ឋានៈធំជាង
ឬ ចៅហ្វាយនាយ (MOUTH LEVEL)



១_ កម្ពស់ដើមទ្រូង : វ័យ ឋានៈស្មើគ្នា ឬ
មិត្តភក្តិ (CHEST LEVEL)



១. ដៃសំពះ ជារាងផ្កាឈូកក្រពុំ

*1. Sampeah Posture in Budding Lotus Shape*



២. សំពះ រវាងបុរស និង ស្ត្រី ឋានៈស្មើគ្នា (ដៃត្រឹមដើមទ្រូង)

*2. Sampeah between a Man and a Woman (Hands at Chest Level)*



៣. សំពះ រវាងក្មេង និង មនុស្សចាស់ ឬ ចៅហ្វាយនាយ (ក្មេងដៃត្រឹមមាត់ ចាស់ដៃត្រឹមដើមទ្រូង)

***3. Sampeah between a Young Person and an Elder or Person of Higher Rank***

***(Younger at Mouth Level, Elder at Chest Level)***



៤. សំពះមាតាបិតា ជីដូនជីតា ឬ គ្រូបាអាចារ្យ (ក្មេងដៃត្រឹមចុងច្រមុះ ចាស់ដៃត្រឹមដើមទ្រូង)

***4. Sampeah to Parents, Grandparents or Elder Masters***

***( Younger at Nose Level, Elder at Chest Level )***

# វិធីថ្វាយបង្គំព្រះមហាក្សត្រ

- "ក្រាប" មានន័យថា : ឱនក្បាលរាបដល់ទីរាបបំផុត (ជួន ណាត ១៩៦៧ ទំព័រ ៨៤) ។
- "ថ្វាយបង្គំ" មានន័យថា : សំពះ តាមសណ្ដាប់សេចក្ដីគោរព (ជួន ណាត ១៩៦៧ ទំព័រ ៥២៩ - ៥៣០) ។
- "ក្រាបថ្វាយបង្គំ" មានន័យថា : ក្រាបសំពះដោយគោរពជាទីបំផុត ។

## វិធីថ្វាយបង្គំគាល់

"ថ្វាយបង្គំគាល់" មានន័យថា : អង្គុយក្នុងតំណាក់ស្ដេច ហើយសំពះដោយគោរព (ជួន ណាត ១៩៦៧ ទំព័រ ១៣៣) នៅពេលសវនាការ ឬស្ដាប់ព្រះឱង្ការព្រះមហាក្សត្រដែលប្រព្រឹត្តទៅក្នុងរយៈពេលយូរ ។ តិរិយាបថថ្វាយបង្គំគាល់គឺគេអង្គុយបត់ជើង (ជើងបត់ទៅខាងស្ដាំ) ហើយលើកដៃសំពះដោយគោរព *(រូបទី៥)* ប៉ុន្តែជាទូទៅសព្វថ្ងៃនេះគេនិយម អង្គុយនៅលើកៅអី ហើយលើកដៃសំពះដោយគោរពទៅវិញ ។

## វិធីថ្វាយបង្គំចំពោះវត្តមាន និងថ្វាយបង្គំលា

ថ្វាយបង្គំចំពោះវត្តមាន និងថ្វាយបង្គំលា ជាតិរិយាបថ និងគារវកិច្ចគោរពដ៏ខ្ពង់ខ្ពស់ ធ្វើទៅពេលថ្វាយបង្គំទូល និង ថ្វាយបង្គំលា ចំពោះវត្តមានព្រះមហាក្សត្រក្នុងរយៈពេលខ្លី ។ ជាទូទៅសព្វថ្ងៃនេះយើងសង្កេតឃើញថា របៀបថ្វាយបង្គំចំពោះវត្តមាន និងថ្វាយបង្គំលាព្រះមហាក្សត្រគឺអង្គុយលុតជង្គង់ម្ខាងផ្ទាល់នឹងក្ដារ ឬ កម្រាល ឯជង្គង់ម្ខាងទៀតបញ្ឈរ ហើយសំពះដោយគោរព ដោយលើកដៃប្រណម្យដាក់ចុងម្រាមដៃនៅត្រឹមចិញ្ចើមរួចបន្ទន់ខ្លួនទៅមុខបន្តិច និង ឱនក្បាលចុះបន្តិច ។ យើងគួរ បញ្ជាក់បន្ថែមផងដែរថា នៅពេលថ្វាយបង្គំព្រះមហាក្សត្រ គេមិនឱ្យងើបមុខឡើង មើលព្រះភ័ក្ត្ររបស់ព្រះអង្គឡើយ *(រូបទី៦)* ។

# ROYAL SALUTATION

Traditionally, when the country folks or the commoners meet someone whom they consider a great personage, such as King or Queen, a prince or princess, or a dignitary, who commands the highest respect, they will instinctively sit down on their heels or haunches, with the hands raised in a budding lotus shape, as a sign of great respect. Not until the high personage has passed or departed will they resume to a normal position.

If a person crouches on the floor before a great personage, such as the King or Queen, in the Khmer traditional fashion with the appropriate posture, that is sideways with the legs folded backward and inward (to the right side), she must recline slightly sideways with the hands in a budding lotus shape resting on the floor as a support.

- "ក្រាប *Krab*" means "lowering the head to the lowest position possible; bending down; ducking; prostrating" (Chuon 1967:84).
- "ថ្វាយបង្គំ *Thvay bangkum*" *means* "saluting with respect" (Chuon 1967:529-530).
- "ក្រាបថ្វាយបង្គំ *Krab thvay bangkum*" means "bending down to salute (while sitting) with great respect."

## *THVAY BANGKUM KOAL*

"ថ្វាយបង្គំគាល់ *Thvay bangkum koal*" means "sitting in the royal abode while saluting with great respect," during a royal audience or while listening to a royal speech in a long period of time (Chuon 1967:133). The manner of *thvay bangkum koal* is crouching (bending both legs to the right) while raising the budding lotus hands to salute with respect. However nowadays, people prefer sitting on a chair and assume the act of *sampeah* instead.

## *THVAY BANGKUM* IN THE PRESENCE OF A KING

*Thvay bangkum* or salutation in the presence of a king is a reverential act with great respect for a king. This act of *thvay bangkum* is done when meeting and leaving the king in a rather short period of time. The manner in which the act of *thvay bangkum* is done is kneeling with one knee on the floor (ground or carpet) while the other is straight up. The hands in the budding lotus shape are assumed with the tip of the fingers at the eyebrow level, the body slightly stoops forward and the head slightly bends down.



៥. ថ្វាយបង្គំគាល់ព្រះមហាក្សត្រ (ដៃត្រឹមប្រជុំចិញ្ចើម)

**5. *Thvay Bangkum Koal before a King (Hands at Eyebrow Level)***



៦. ថ្វាយបង្គំចំពោះវត្តមាន និងថ្វាយបង្គំលាព្រះមហាក្សត្រ (ដៃត្រឹមប្រជុំចិញ្ចើម)

*6. Thvay Bangkum before a King (Hands at Eyebrow Level)*



៧. ក្រាបថ្វាយបង្គំចំពោះវត្តមាន និងក្រាបថ្វាយបង្គំលាព្រះមហាក្សត្រ (ដៃត្រឹមប្រជុំចិញ្ចើម)

***7. Thvay Bangkum before a King (Hands at Eyebrow Level)***

# វិធីសំពះក្នុងរបាំ

ការគោរពជាលក្ខណៈ និង ជាសារៈសំខាន់មួយនៅក្នុងជីវិតប្រពៃណី និង សង្គមខ្មែរ ។ លក្ខណៈ និង សារៈសំខាន់នេះ ខ្មែរយើងបានថែរក្សាតាំងពីយូរលង់ណាស់មកហើយរហូតដល់សព្វថ្ងៃនេះ ហើយមិនត្រឹមតែប្រតិបត្តិ និង អនុវត្តន៍នៅក្នុងជីវិត ធម្មតារាល់ថ្ងៃប៉ុណ្ណោះទេ ថែមទាំងបញ្ចូលទៅក្នុងសិល្បៈប្រពៃណីផ្សេងៗដូចជារបាំក្បាច់បុរាណជាដើមទៀតផង ។ សំពះនៅក្នុងរបាំមានសភាពខុសប្លែកពីសំពះក្នុងជីវិតធម្មតា ពោលគឺមានលក្ខណៈកែច្នៃលំអឱ្យមានសោភ័ណភាពជាសិល្បៈ ។ លក្ខណៈពិសេសដែលខុសគ្នា គឺស្ថិតនៅត្រង់ម្រាមដៃដែលបត់អើន ជារាងផ្កាឈូករីក ( មិនក្រពុំ) *(រូបទី៨)* ។

ម្យ៉ាងទៀតកម្រិតកម្ពស់ និង អត្ថន័យរបស់សំពះនៅក្នុងរបាំខ្មែរ មានបីសណ្ឋានគឺ :

*១-សំពះដោយដាក់ដៃរាងផ្កាឈូករីកនៅលើដើមទ្រូងគឺសំពះទៅអ្នកធំ ដូចជាព្រះមហាក្សត្រ (រូបទី៩)* ។

*២-សំពះដោយដាក់ដៃរាងផ្កាឈូករីកនៅលើថ្ងាសគឺសំពះទៅព្រះអាទិទេព គ្រូបាធ្យាយ ឬ វត្ថុសក្ដិសិទ្ធិ (រូបទី១០)* ។

*៣-សំពះដោយដាក់ដៃរាងផ្កាឈូករីកត្រឡប់មកនៅលើដើមទ្រូងវិញ គឺសំពះទៅទស្សនិកជន និង មនុស្ស សាមញ្ញធម្មតា (រូបទី១១ ខាងលើ )* ។

✦ យើងសូមបញ្ជាក់ថា ការសំពះទាំងបីនៅក្នុងរបាំខ្មែរត្រូវធ្វើឡើងជាបន្តបន្ទាប់គ្នាតាមលេខរៀងដូច ដែលមានបង្ហាញជូនខាងលើនេះ ។ ( មើលបន្ថែម **Khmer Court Dance: A Comprehensive Study of Movements, Gestures, and Postures as Applied Techniques** ដោយ សំ ចន្រ្ទមូលី (១៩៨៧) ) ។

កិរិយាបថសំពះ អាចសង្កេតឃើញមានជារឿយៗ ក្នុងរបាំក្បាច់បុរាណខ្មែរ នៅពេល :

- វំពូកគុណគ្រូ ក្នុងបន្ទប់ស្លៀកពាក់ មុននឹងចេញសំដែង មុននឹងពាក់មកុដ ឬ មុខ
- មុននឹងចេញសំដែងក្នុងឆាក

# *SAMPEAH* IN DANCE CONTEXT

One cannot stress enough the importance of showing respect and gratitude in Khmer life. This concept is inherently practiced and incorporated into Khmer dance. In the dance context, the *sampeah* posture, in its idealized form, may be often seen on stage in the របាំក្បាច់បុរាណខ្មែរ Khmer court dance and ល្ខោនក្បាច់បុរាណខ្មែរ dance drama performances. Here, one is able to observe the artistic movements of the hands of a dancer, who, before performing the *sampeah*, will place her hands, joined palm to palm, with the fingertips drawn slightly from each other.

Khmer court dancers use the *sampeah* posture in stylized manner. It is executed by joining both palms together with the fingers arched backward into dramatic curvatures as the Khmer dance is characterized. This reverential salutation or *sampeah* is also known as អញ្ជលី *anchali (anjali)* or ប្រណម្យ *pranamm.* This gesture occurs frequently and is seen an average of one to two times in each dance piece. For example, in របាំអប្សរា Robaim Apsara (Apsara Dance) របាំផ្លិត Robaim Phlett (Fan Dance) and របាំទេពមនោរម្យ Robaim Tep Monorum (Happiness of the Gods and Goddesses Dance) when dancers enter in procession and encircle the dance floor, upon arriving at their place, they take their kneeling posture. Synchronizing with music, at the end of the piece, both palms are joined together and brought up to the forehead and back to the chest level. Religiously originated, the *sampeah* is highly ritualized in three gradual and orderly steps embodying three important principles and meanings.

1. *Sampeah* on the chest is to a high personage such as a king.
2. *Sampeah* at the forehead is to the divinity, teacher or sacred object.
3. *Sampeah* back at the chest is the salute to the audience or a person of an equal status.

The act of preservation has always been strongly maintained by Khmer artists both in Cambodia and abroad. It can be observed auspiciously and intimately before each performance on stage, in the dressing room, and backstage. In the dressing room, before the masks and headdresses are put on, an act of *sampeah* is expected in honoring the

- ក្រោយពេលចេញផុតពីឆាក
- ពេលឮសូរភ្លេងសាធុការ ( ភ្លេងរំឭកគុណគ្រូ )

នៅក្នុងរបាំខ្លះដូចជា របាំអប្សរា របាំទេពមនោរម្យ និង របាំផ្លិតគេសង្កេតឃើញមានសំពះម្តងទៅពីរដង ម្តងនៅពេលដែលអ្នករាំលុតជង្គង់ចុះនៅកណ្តាលឆាក និង ម្តងទៀត នៅចុងបញ្ចប់នៃរបាំ គឺនៅពេលដែលអ្នករាំតម្រៀបគ្នាជាគូមុននឹងចេញពីឆាក ។

teachers and for the teacher's spirit of the dancers' particular roles to be with them throughout the performance. The Khmers believe that spirits reside in the masks and headdresses, and thus protect and bless the dancers and their apprenticeship. We also believe that our teacher's spirits reside on our head. Thus, we are insulted when someone touches our head. When the សំភោរ *sampho* (small double-headed barrel drum) player strikes the first beat for the invocation of the spirit to the music សាធុការ Sathukar,[1] everyone, with hands joined together and placed above the head, *sampeah* or salute. Before the entrance into and the exit out of the dance floor, dancers *sampeah* in a brief moment for bliss and gratitude to the teachers.

[1] Sathukar is a spiritual piece normally performed for the invocation of the spirit of deceased teachers.



៨. ដៃសំពះក្នុងរបាំរាងផ្កាឈូករីក

***8. Sampeah Dance Posture with Lotus Blossom Shape***



៩. អញ្ជលីប្រណម្យលើដើមទ្រូងក្នុងរបាំ (ដៃត្រឹមដើមទ្រូង)

*9. Sampeah Dance Posture (Hands at Chest Level)*



១០. អញ្ជលីប្រណាម្យលើសិរីសាក្នុងរបាំ (ដៃត្រឹមថ្ងាស)

***10. Sampeah Dance Posture (Hands at Forehead Level)***





១១. អញ្ជលីប្រណម្យក្នុងរបាំ

***11. Sampeah Dance Posture***

# វិធីក្រាបថ្វាយបង្គំក្នុង ព្រះពុទ្ធសាសនា

យើងហៅក្រាបថ្វាយបង្គំថា " *បញ្ចប្រណាម្យ* " ឬ " *បញ្ចអង្គប្រណាម្យ* " សំដៅទៅលើការគោរពសំពះដោយប្រាំចំណែកនៃអង្គប្រាណ មានថ្ងាស១ ដៃ២ និង ជង្គង់២។ ន័យរបស់ក្រាបថ្វាយបង្គំ រួមបញ្ចូលទាំងឥរិយាបថលុតជង្គង់សំពះ និង ថ្វាយបង្គំព្រះផងដែរ *(រូបទី១២)* ។ ក្រាបថ្វាយបង្គំ មានន័យថាអង្គុយបត់ជើង (ជើងបត់ទៅខាងស្តាំ) ដៃលើកឡើង សំពះ ប្រកបដោយផងខ្លួនក្រាបចុះ កែងដៃទាំងពីរដាក់ចុះ ផ្ទាល់ទៅនឹងក្តារឬកម្រាល *(រូបទី១៣)* ។ ន័យដើមរបស់ក្រាបថ្វាយបង្គំ គឺសំដៅទៅលើការគោរពដ៏ជ្រាលជ្រៅ និង ឧត្តុង្គឧត្តមចំពោះព្រះរតនត្រៃ ពោលគឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ដូច្នេះហើយបានជាយើងតែងតែថ្វាយបង្គំបីដងជាប់ៗគ្នា ។ ការក្រាបថ្វាយបង្គំបីដងនេះ គឺលើកទី១ និង ទី២ គេគ្រាន់តែឱនក្បាល និង ផងខ្លួនចុះបន្តិចដល់លើកទី៣ទើបគេឱនក្បាលដល់ក្រោមប៉ះនឹងដៃទាំងពីរ *(រូបទី១៤ ១៥ ១៦ ១៧)* ។

នៅតាមទីវត្តអារាម ឬផ្ទះក្នុងឱកាសដែលព្រះសង្ឃសម្តែងព្រះធម្មទេសនា ឬ សូត្រមន្ត ពុទ្ធបរិស័ទត្រូវតែលើកដៃសំពះ ឬ ប្រណម្យតាំងពីដើមដល់ចប់ ។ ព្រះ សង្ឃនៅក្នុង ព្រះពុទ្ធសាសនា (យោងទៅលើគុណធម៌) មិនតម្រូវឱ្យព្រះសង្ឃ សំពះតបទៅនឹងឧបាសក ឧបាសិកាវិញឡើយ ទោះបីមាន អាយុចាស់ជាង ឬ ឋានន្តរសក្តិធំ សូម្បីតែស្តេចផែនដីក៏ដោយ ។ ព្រះសង្ឃត្រឹមតែតបវិញដោយវាចាថា "ចម្រើនពរ" ឬ យកព្រះហស្តមកប៉ះនឹងឧបាសក ឬ ដោយប្រើទឹកមុខតបទៅវិញតែ ប៉ុណ្ណោះ ។

# *KRAB THVAY BANGKUM* IN RELIGIOUS CONTEXT

We refer to *krab thvay bangkum* also as បញ្ចប្រណាម្យ *pancha pranamm* or បញ្ចអង្គប្រណាម្យ *pancha ang pranamm* meaning "a revered salutation with the five members of the body organs, i.e., the forehead, the two palms of the hands, and the two knees touching the floor." Originally, the *krab* was meant as a sign of profound worship to the Triple Gems of Buddhism, i.e., the Buddha, his Law, and his Brotherhood of Monks. Consequently, the *krab* is executed three times in repetition. In the kneeling position, a woman rests her haunches on her soles instead of resting them on the heels as a man does.

While passing a Buddhist temple, a devout person will make a *sampeah* before it as an act of reverence. During a Buddhist sermon, or while monks recite ritual texts from the Buddhist Holy Scriptures, one will notice that both the monks and the lay members assume a solemn attitude of meekness and obeisance to the sacredness of the ceremony with hands raised all the time in a budding lotus shape.

Buddhist monks by virtue of their saffron robes, will not return the obeisance of *sampeah* to a layman however old or great in rank, not even to the king. This is not, in Khmer etiquette, a presumption on the part of the monks. The appropriate way for a monk to respond in such a situation is by a gesture of acknowledgement either by speech or a facial expression of good will. At least he should assume a serene face as befitting a monk.



១២. ថ្វាយបង្គំព្រះពុទ្ធ ព្រះសង្ឃ របៀបបុរស

*12. Thvay Bangkum before a Monk or an Altar for a Man*



១៣. ក្រាបថ្វាយបង្គំព្រះពុទ្ធ ព្រះសង្ឃ របៀបបុរស

***13. Krab Thvay Bangkum before a Monk or an Altar for a Man***



១៤. ថ្វាយបង្គំព្រះពុទ្ធ របៀបបុរស

***14. Thvay Bangkum before a Monk or an Altar for a Man***



១៥. ក្រាបថ្វាយបង្គំព្រះពុទ្ធ របៀបបុរស

*15. Krab Thvay Bangkum before a Monk or an Altar for a Man*



១៦. ថ្វាយបង្គំព្រះពុទ្ធ ព្រះសង្ឃ របៀបស្ត្រី

***16. Thvay Bangkum before a Monk or an Altar for a Woman***



១៧. ក្រាបថ្វាយបង្គំព្រះពុទ្ធ ព្រះសង្ឃ របៀបស្រ្តី

*17. Krab Thvay Bangkum before a Monk or an Altar for a Woman*



១៨. ថ្វាយបង្គំព្រះ ឬ បួងសួង វត្ថុសក្តិសិទ្ធិសក្ការៈ

***18. Thvay Bangkum before a Monk or an Altar for a Woman***

# ពិធីក្រាបសំពះក្នុងអាពាហ៍ពិពាហ៍

ពិធីអាពាហ៍ពិពាហ៍ ជាទំនៀមទម្លាប់ប្រពៃណីបុរាណមួយ ដែលខ្មែរយើងបានថែរក្សារហូតមកដល់សព្វថ្ងៃ។ ពិធី នេះមាន សភាពរីករាយ អធិកអធមណាស់ ព្រោះជាពិធីមង្គល ផ្តល់សិរីសួស្តី ដល់គូស្វាមីភរិយាដែលទើប នឹងរៀប ... រឹងចាត់ទុក ពិធីអាពាហ៍ពិពាហ៍ជាពិធីដ៏សំខាន់មួ ... ប ដែលគេម្នាក់ៗត្រូវតែឆ្លងកាត់។ កន្លង ... ថា នាសម័យបុរាណខ្មែរយើងរៀបចំប្រា ... ក្នុងរយៈពេលប្រាំពីរយប់ ប្រាំពីរថ្ងៃ។ យោង ... ថវិកា និង ពេលវេលាព្រមទាំងកាលៈទេសៈបច្ចុប្ប ... អាពាហ៍ពិពាហ៍បានត្រូវបន្ថយមកនៅត្រឹមតែបីយប់បីថ្ងៃ ឥឡូវនេះ នៅសល់តែមួយយប់ មួយថ្ងៃប៉ុណ្ណោះ ។

ពិធីអាពាហ៍ពិពាហ៍ខ្មែរមានរួមបញ្ចូលនូវពិធីតូចៗ ជាច្រើន ដូចជាពិធីលើកជំនូន ពិធីចូលរោង ពិធីហែកូនកំលោះ ពិធី កាត់ខាន់ស្លា ពិធីបង្វិលពពិល ពិធីកាត់សក់ និង ពិធីផ្ទឹមចងដៃ ជាដើម។ នៅក្នុងពិធីផ្ទឹមចងដៃនេះ កូនប្រុស កូនស្រី ចេញមក ក្រាបសំពះផ្ទឹម ដោយមានតន្ត្រីខ្មែរកំដរ គគ្រឹកគគ្រេង និង ពីរោះលន្លង់លន្លោចផង ។ កូនប្រុស កូនស្រីក្រាបសំពះផ្ទឹម និង ដាក់ដៃទាំងពីរសំពះលើខ្នើយ នៅកណ្តាលវង់ដែលព័ទ្ធជុំវិញ ដោយ ភ្ញៀវកិត្តិយស មេបាចាស់ទុំ ឪពុកម្តាយ ញាតិសាច់សារលោហិត ទាំងអស់ដើម្បីចងដៃ និង ប្រសិទ្ធិពរជ័យ សិរីមង្គលដល់ គូស្វាមីភរិយាថ្មី ឱ្យរកស៊ីមានបាន មានជោគជ័យ និង សុភមង្គល ក្នុងដំណើរជីវិត ទៅអនាគត។ (មើលបន្ថែម ម៉ៅ ភឿង (១៩៩៨), ពេជ្រ សល់ (១៩៧០)) ។

ជាអវសាន ទូលព្រះបង្គំយើងខ្ញុំជាអ្នកនិពន្ធ សង្ឃឹមថា កម្រងសៀវភៅដ៏តូចនេះបានផ្តល់ជាពត៌មាន គំនិតក្បូនខ្នាត និង សតិខ្លះ ថ្វាយចំពោះ សម្តេច ព្រះអង្គ ព្រះ អង្គម្ចាស់ អ្នកអង្គម្ចាស់ អ្នកម្នាង និង ជូនដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាដែលបានទត និង អាននូវកម្រងស្នាដៃនេះដែលជា ប្រធានបទមួយ ស្តីពីការបង្ហាញ *របៀបសំពះខ្មែរ* សំរាប់ ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ទាំងចាស់ ទាំងក្មេង គួរបដិបត្តិជារៀង រាល់ថ្ងៃ ។

# *KRAB SAMPEAH* IN WEDDING

The wedding is a traditional ceremony which has been preserved by the Khmers since the olden days. Although the length of the ceremony has been curtailed from seven days and seven nights to three days and three nights, and now a mere one day, or even half a day with a reception and banquet in the evening to conclude it, the Khmers consider it as an important event in life.

During the course of the entire wedding ceremony, there are several rituals, such as the ចូលម្លប់ . ... tering the Shade លើកជំនូន Presentation of a ... y, ចូលរោង Entering the Wedding Quarter, ... ះ Groom Procession, កាត់ខាន់ស្លា Dowry ... , បង្វិលពពិល Turning or Passing the ពពិល ... ក់ Hair-Cutting, and ផ្ទឹម Prostration. In ... e bride and groom prostrate (with the ... wedding music) for the parents, ı ... ds to come forward and tie the co ... their wrists for happiness and bliss.

បើមាន ការខ្វះខាត ឬ ខុសឆ្គងត្រង់អន្លើណាមួយ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះមេត្តាខន្តី អភ័យទោស និង រង់ចាំទទួលនូវការជួយណែនាំសរសេរបំភ្លឺបន្ថែម ដើម្បីកែលំអកម្រងនេះឱ្យរឹតតែសុក្រឹតប្រសើរឡើងថែមទៀត ។





១៩. សំពះថ្លើមក្នុងអាពាហ៍ពិពាហ៍

***19. Sampeah in Wedding Ceremony***

# ឯកសារពិគ្រោះ

## REFERENCES CITED


ជួន ណាត

១៩៦៧ **វចនានុក្រមខ្មែរ** ។ ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។

ពេជ្រ សល់

១៩៧០ **អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ** ។ ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។

ម៉ៅ ភឿង

១៩៩៨ **ស្វែងយល់ជុំវិញសិល្បៈតន្ត្រីខ្មែរ** ។ ភ្នំពេញ : ម៉ៅ ភឿង ។

**Musique Khmere**

1969 Phnom Penh: Imprimerie Sangkum Reastr Niyum.

Nou, Ker, et Nhieuk Nou

1973 *"Kpuon Abah-Bibah ou Le Livre de Mariage des Khmers,"* **Bulletin de l'Ecole Francaise d'Extreme-Orient** 60:243-328.

Rajadhon, Anuman

1990 **Thai Traditional Salutation.** Bangkok: The Fine Arts Department.

Sam, Chan Moly

1987 **Khmer Court Dance: A Comprehensive Study of Movements, Gestures, and Postures as Applied Techniques.** Newington: Khmer Studies Institute.

CAMBODIA

17/07-02
$10.00

Monument Books
0211100022315

FIRST PRINTING 2,500 COPIES
SPONSORED BY UNESCO CAMBODIA
JANUARY 2002